# សុន្ទរកថា

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងពិធីបើកមហាសន្និបាតលើកទី ៨ របស់សភាតំបន់អាស៊ី (APA)

## «ការជំរុញសន្តិភាព, ការផ្សះផ្សា និង ការសន្ទនា នៅតំបន់អាស៊ី»

## រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥

- *ឯកឧត្តម **មៀន រ៉ាហ្សារ៉ាបានី** (MIAN Raza Rabbani) ប្រធានសភាតំបន់អាស៊ី;*
- *សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា;*
- *សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា;*
- *ឯកឧត្តម **នីចាត់ ហូសេនៀន** (NEJAD Hosseinian) អគ្គលេខាធិការសភាតំបន់អាស៊ី;*
- *ឯកឧត្តម, លោកជំទាវ, សមាជិក- សមាជិកានៃគណៈប្រតិភូមកពីសភាតំបន់អាស៊ី, ប្រទេសសង្កេតការណ៍ និង អង្គការសង្កេតការណ៍;*
- *ឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ- អន្តរជាតិ ជាទីមេត្រី !*

ថ្ងៃនេះ, ខ្ញុំមានកិត្តិយស និង សេចក្ដីរីករាយក្រៃលែង ដោយបានចូលរួមក្នុងពិធីបើកមហាសន្និបាតលើកទី ៨ នៃសភាតំបន់អាស៊ី ដែលត្រូវបានរៀបចំយ៉ាងឱឡារិក នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងនាមរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា, ខ្ញុំសូមសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅបំផុត ជូនចំពោះសមាជិក- សមាជិកាសភានៃបណ្ដាប្រទេសជាសមាជិកសភាតំបន់អាស៊ី, ប្រទេសសង្កេតការណ៍ និង គណៈប្រតិភូទាំងអស់ ដែលបានចូលរួមក្នុងមហាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយនេះ ។ កម្ពុជាពិតជាមានមោទនភាពដ៏ខ្ពង់ខ្ពស់ ដែលទទួលបាននូវមហាកិត្តិយស ធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតនៃសភាតំបន់អាស៊ី ។

មហាសន្និបាតលើកទី ៨ នៃសភាតំបន់អាស៊ី ក្រោមប្រធានបទ **«ការជំរុញសន្តិភាព, ការផ្សះផ្សា និង ការសន្ទនា នៅតំបន់អាស៊ី»** នេះ ពិតជាមានសារៈសំខាន់, មិនត្រឹមតែសម្រាប់ការបំផុសស្មារតីរបស់យើង ឱ្យរួមគ្នាឆ្លើយតបទាន់ពេលទៅនឹងសភាពការណ៍វិវត្តរបស់តំបន់ និង ពិភពលោក ដែលកំពុងតែញាំញីដោយរងើកភ្លើងនៃជម្លោះ និង សង្គ្រាម ព្រម-ទាំងការរីករាលដាលនៃអំពើភេរវកម្មដ៏គ្រោះថ្នាក់បំផុតសម្រាប់មនុស្សជាតិទាំងមូលប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងសម្រាប់ការរួមចំណែកលើកកម្ពស់ការយល់ដឹងឱ្យបានកាន់តែទូលំទូលាយ អំពីអត្ថន័យ និង តម្លៃនៃសន្តិភាព និង ភាពចាំបាច់ ក្នុងការរួមចំណែករបស់យើងម្នាក់ៗ ដល់កិច្ចប្រឹងប្រែងជាអន្តរជាតិ សំដៅទប់ស្កាត់, កាត់បន្ថយ និង បញ្ឈប់រាល់ជម្លោះប្រដាប់អាវុធ និង សង្គ្រាម នៅគ្រប់ទីកន្លែងទូទាំងពិភពលោកផងដែរ ។

នៅក្រោមប្រធានបទនេះ, អនុញ្ញាតឱ្យខ្ញុំគួសរំលេចឡើងវិញខ្លះៗ អំពីបទពិសោធ៍ជាក់ស្ដែងដែលកម្ពុជាបានជួបប្រទះក្នុងការឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាម ដែលបង្កការឈឺចាប់ខ្លោចផ្សារមិនអាចថ្លាថ្លែងបាន ចំពោះប្រជាជនកម្ពុជាទាំងមូល

ហើយនៅបន្សល់ស្លាកស្នាមមិនទាន់រលុបអស់នៅឡើយមកទល់បច្ចុប្បន្ននេះ ។ ដូចអស់លោកអ្នកទាំងអស់គ្នាជ្រាបស្រាប់, នាដើមសហស្សវត្សរ៍ដែលកន្លងផុតទៅនេះ កម្ពុជាបានឈានឡើងដល់កំពូលនៃភាពរុងរឿងល្បីល្បាញត្រចះត្រចង់ ។ យើងធ្លាប់បានប្រើប្រាស់បច្ចេកវិទ្យាដ៏ទំនើបនាសម័យនោះ ក្នុងផ្នែកនិម្មាបនកម្ម, កសិកម្ម, នគរោបនីយកម្ម និង ការ-សាងសង់ផ្សេងៗជាច្រើន ។ ក៏ប៉ុន្តែសង្គ្រាមស៊ីវិល និង កលិយុគ ដែលបណ្ដាលមកពីការបែកបាក់ផ្ទៃក្នុង តាំងពីសតវត្សរ៍ទី ១៤ មក ព្រមទាំងជម្លោះមនោគមន៍វិជ្ជានៃមហាអំណាចខាងក្រៅ ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនៃសតវត្សរ៍ទី ២០ បានរុញច្រានកម្ពុជាឱ្យធ្លាក់ចូលទៅក្នុងរណ្ដៅនៃភាពអន្ធការ ។ នៅដើមទសវត្សរ៍ឆ្នាំ ៧០, កម្ពុជាបានទទួលរងនូវការ-បែកបាក់កាន់តែខ្លាំង ដោយសាររដ្ឋប្រហារថ្ងៃ ១៨ មីនា ១៩៧០ ដឹកនាំដោយសេនាប្រមុខ **លន់ ណុល** ទម្លាក់របបសម្ដេចព្រះ **នរោត្តម សីហនុ** ដែលធ្វើឱ្យកម្ពុជារមិលចូលក្នុងភ្នក់ភ្លើងសង្គ្រាមដ៏ជ្រៅ ។ គ្រាប់បែករាប់ពាន់តោន ត្រូវបានទម្លាក់លើទឹកដីកម្ពុជា, ប្រជាជនរាប់លាននាក់ បានស្លាប់បាត់បង់ជីវិត, ធ្លាក់ខ្លួនពិការ, វិនាសព្រាត់ប្រាស់គ្រួសារ និង បាត់បង់ទ្រព្យសម្បត្តិ ។ ឈានដល់ពាក់កណ្ដាលទសវត្សរ៍ឆ្នាំ ៧០, កម្ពុជាកាន់តែទទួលរងនូវវិនាសកម្មបន្ថែមទៀត នៅក្រោមរបបវាលពិឃាដរបស់ពួកខ្មែរក្រហម ដែលបានបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់ប្រជាជន និង បានប្រល័យជីវិតជនកម្ពុជាស្លូតត្រង់ អស់ប្រមាណបីលាននាក់ ។

នៅថ្ងៃ ៧ មករា ១៩៧៩, ប្រទេស និង ប្រជាជនកម្ពុជាទាំងមូល ត្រូវបានរំដោះឱ្យរួចផុតប្រញាំបីសាចនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដោយសារកម្លាំងមហាសាមគ្គីនៃកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ ជាបន្តបន្ទាប់, កម្ពុជាបានខិតខំកសាង និង អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ឱ្យរីកចម្រើនល្អគួរជាលំដាប់ ក្នុងសភាពការណ៍ **«មានសង្គ្រាមផង និង មានសន្តិភាពផង»** ។ ដោយយល់ច្បាស់ពីបំណងប្រាថ្នាចង់បានសុខសន្តិភាពរបស់ប្រជាជន, យើងបានចាប់ផ្ដើមធ្វើការចរចាស្វែងរកដំណោះស្រាយនយោបាយ រហូតដល់សម្រេចបាននូវ **«កិច្ចព្រមព្រៀងទីក្រុងប៉ារីស»** នៅឆ្នាំ ១៩៩១ ។ ស្របតាមកិច្ចព្រមព្រៀងនេះ សហគមន៍អន្តរជាតិបានរៀបចំឱ្យមានការបោះឆ្នោតជាសកលមួយសម្រាប់កម្ពុជា នៅក្នុងឆ្នាំ ១៩៩៣ ដែលប្រសូត្រចេញជារដ្ឋាភិបាលចម្រុះមួយ ដោយបន្សល់ទុកភាគីមួយឱ្យនៅខាងក្រៅចរន្តនៃសង្គមជាតិ ហើយបន្តសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាល ។ រហូតដល់ឆ្នាំ ១៩៩៨, តាមរយៈនយោបាយ **«ឈ្នះ-ឈ្នះ»**, ទើបកម្ពុជាអាចសម្រេចបាននូវការបង្រួបបង្រួមជាតិ និងផ្សះផ្សាជាតិ ដោយខ្លួនឯង, ដោយគ្មានការបង្គាប់បញ្ជា ឬ បញ្ចុះបញ្ចូលពីខាងក្រៅ ។ លើមូលដ្ឋាននេះ, សង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សរ៍ ត្រូវបានបញ្ចប់ ហើយប្រទេសជាតិក៏ទទួលបានមកវិញយ៉ាងពេញលេញ នូវសន្តិភាព, ការឯកភាពជាតិ និង បូរណភាពទឹកដី ដោយសារការខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញ ដើម្បីការបង្រួមបង្រួមជាតិ និង ការជានាជាតិ **តាមរយៈការសម្រុះសម្រួល និង ការធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក** ។

នេះ គឺជាសច្ចភាពនៃដំណើររស់ឡើងវិញរបស់សង្គមជាតិកម្ពុជា ដែលបានធ្វើឱ្យប្រជាជាតិយើងយល់យ៉ាងច្បាស់អំពីគុណតម្លៃនៃសុខសន្តិភាព ហើយតែងប្រាថ្នាមិនឱ្យបាត់បង់ទៅវិញជាដាច់ខាត ។ ផលនៃសន្តិភាពនេះ ក៏បានរួមចំណែកដ៏ខ្លាំងក្លាដល់កិច្ចដំណើរការពង្រឹងលទ្ធិប្រជាធិបតេយ្យ, ការគោរពសិទ្ធិ និង សេចក្ដីថ្លៃថ្នូររបស់មនុស្សផងដែរ ។ បទពិសោធន៍ទាំងអស់នេះ បានធ្វើឱ្យប្រជាជាតិកម្ពុជា មានសុឆន្ទៈមោះមុត, ជ្រោងខ្ពស់ទង់នៃការផ្សះផ្សាជាតិ, ការពារសន្តិភាព, ស្ថិរភាព និង សណ្ដាប់ធ្នាប់សង្គម, ការគោរពរដ្ឋធម្មនុញ្ញ និង ច្បាប់រដ្ឋ ដើម្បីជាផលប្រយោជន៍រួមរបស់ប្រជាជន, សង្គមជាតិ និង មាតុភូមិ ។

ច្បាស់ណាស់ថា ការបញ្ចប់ដោយជោគជ័យ និង ដោយសន្តិវិធី នូវសង្គ្រាម និង ការបែកបាក់ជាតិ គឺពិតជាសម្រេចបានមកដោយលំបាកបំផុត ។ ក៏ប៉ុន្តែ ការធានានូវចិរភាពនៃសុខសន្តិភាព និង ការពង្រឹងថែមទៀត នូវវប្បធម៌សន្តិភាពដែលសម្រេចបានមកនេះ គឺជាភារកិច្ចដែលរឹតតែលំបាកធ្ងន់ធ្ងរណាស់ទៅទៀត ។ ក្នុងគោលដៅនេះ យើងត្រូវតែធ្វើការយ៉ាងស្វាហាប់ និង ត្រូវខិតខំប្រឹងប្រែងទ្វេរឡើងថែមទៀត ដើម្បីថែបំប៉នជាប្រចាំនូវរាល់កត្តាសំខាន់ៗទាំងឡាយដែលជាឫសគល់នៃសន្តិភាព ដែលក្នុងនោះរួមមានជាអាទិ៍ : ការលើកកម្ពស់វប្បធម៌នៃភាពអហិង្សា, ការគោរពសិទ្ធ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស, ការលើកតម្កើងលិទ្ធិប្រជាធិបតេយ្យ និង អភិបាលកិច្ចល្អ ព្រមទាំងការគោរពយ៉ាងហ្មឹងម៉ាត់ឥតងាករេនូវ **«នីតិរដ្ឋ»** ហើយជាពិសេសបំផុត គឺការខិតខំកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស និង ការកែលម្អជីវភាពរបស់ប្រជាជន ។ គ្មានការខិតខំ និង គ្មានលទ្ធផលជាក់ស្តែងនៅក្នុងការអនុវត្តន៍កិច្ចការទាំងអស់នេះ, យើងប្រាកដជាមិនអាចសង្ឃឹមថា នឹងរក្សាបាននូវចិរភាពនៃសុខសន្តិភាពដែលសម្រេចបានដោយលំបាកលំបិនបំផុតនេះទេ ។

**សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, អង្គពិធីទាំងមូល !**

នៅក្នុងតំបន់មួយចំនួននៃពិភពលោកយើងនាបច្ចុប្បន្ននេះ, សន្តិភាពកំពុងតែត្រូវបានគំរាម ដោយសារជម្លោះ, សង្គ្រាម និងអំពើភេរវកម្ម ដែលធ្វើឱ្យបាត់បង់ជីវិតមនុស្ស និង បំផ្លាញទ្រព្យសម្បត្តិអស់ច្រើនសន្ធឹកសន្ធាប់ ។ ហេតុការណ៍ដែលបានកើតឡើងថ្មីៗនៅក្នុងទីក្រុងប៉ារីស ក៏ដូចជាការវាយប្រហារទម្លាក់យន្តហោះអ្នកដំណើររបស់រុស្ស៊ីដោយពួកភេរវករនៅប្រទេសអេហ្ស៊ីប ព្រមទាំងការបាញ់សម្លាប់រង្គាលនៅរដ្ឋកាលីហ្វូនីញ៉ានៃសហរដ្ឋអាមេរិកប៉ុន្មានថ្ងៃមុននេះ បានបញ្ជាក់ជាថ្មីថា អំពើភេរវកម្ម និង ចលនាជ្រុលនិយម នៅតែបន្តគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិសុខ និង ស្ថិរភាព នៅក្នុងពិភពលោក ។ ទន្ទឹមនេះ យើងសង្កេតឃើញថា ចលនាជ្រុលនិយម និង លទ្ធិជ្រុលនិយមនេះ កំពុងតែសាយភាយមកដល់តំបន់ផ្សេងៗ រួមទាំងតំបន់អាស៊ីរបស់យើងផងដែរ ។

បន្ថែមពីលើនេះ, ពិភពលោកយើងក៏កំពុងតែបន្តជួបប្រទះនឹងបញ្ហាប្រឈមធំៗជាច្រើនផ្សេងទៀត រួមមានដូចជាភាពផុយស្រួយនៃការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍន៍ ដែលគួបផ្សំនឹងការអូសបន្លាយនៃវិបត្តិបំណុលនៅតំបន់អឺរ៉ុប, ការថមថយនៃកំណើនសេដ្ឋកិច្ចនៃប្រទេសដែលកំពុងតែស្ទុះងើបឡើង ពិសេសប្រទេសចិន, វិបត្តិនយោបាយ និង សង្គម ដែលកំពុងបន្តកើតមាននៅមជ្ឈិមបូព៌ា និង អាហ្វ្រិកខាងជើង, បញ្ហាសន្តិសុខស្បៀង និង ថាមពល, ការប្រែប្រួលអាកាសធាតុ, គ្រោះមហន្តរាយធម្មជាតិ, ឧក្រិដ្ឋកម្មឆ្លងដែន ជាដើម ។ល។ ដែលសុទ្ធតែអាចបង្កជាបច្ច័យអាក្រក់ដល់ស្ថិរភាព និង សុខសន្តិភាពសម្រាប់ប្រជាជាតិទាំងឡាយ, ទាំងក្នុងកម្រិតសកល, ទាំងក្នុងកម្រិតតំបន់ ។

ប្រការទាំងអស់នេះ បានបញ្ជាក់ពីតម្រូវការនៃការពង្រឹងកិច្ចសហប្រតិបត្តិការ និង កិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិក្នុងគ្រប់កម្រិត ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខនានា ក្នុងគោលដៅធានាចិរភាពនៃការអភិវឌ្ឍ, ស្ថិរភាព, សន្តិសុខ និង សន្តិភាព ព្រមទាំងភាពសុខដុមរមនានៅក្នុងសង្គម ។ ច្បាស់ណាស់ថា កិច្ចខិតខំប្រឹងប្រែងទាំងអស់របស់យើង នៅក្នុងដំណើរការនេះ មិនអាចនឹងផ្តល់លទ្ធផលល្អប្រសើរតាមការរំពឹងទុកនោះឡើយ ប្រសិនបើគ្មានការចូលរួម និង ការគាំទ្រយ៉ាងសកម្ម ពីសំណាក់ប្រជាជនរបស់យើងទាំងអស់គ្នា គ្រប់ស្រទាប់ជាន់ថ្នាក់ ជាពិសេសគឺយុវជន និង

វិស័យឯកជន ។ ដូច្នេះ ការជំរុញលើកកម្ពស់ការចូលរួមនេះ គឺជាអាទិភាពខ្ពស់បំផុតមួយរបស់ប្រជាជាតិយើងទាំងអស់គ្នា ក្នុងរយៈពេលវែងតទៅមុខទៀត ។

ខ្ញុំគិតថា នៅក្នុងកិច្ចដំណើរការនៃការប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការជាអន្តរជាតិរវាងបណ្ដាប្រទេស និង ប្រជាជាតិ និងក្នុងការលើកកម្ពស់ការចូលរួមនេះ, អង្គការនីតិបញ្ញត្តិនៅក្នុងប្រទេសនីមួយៗ, ពិសេសគឺ **«ស្ថាប័នសភា»**, ពិតជាមានតួនាទីដ៏សំខាន់ និង មិនអាចខ្វះបាន ។ ក្នុងនាមជាអង្គការនីតិបញ្ញត្តិរបស់ជាតិនីមួយៗ, **សភា** មានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ និង ការផ្ដល់សច្ចាប័នលើលិខិតូបករណ៍នានា ដែលជួយផ្ដល់ការគាំទ្រ និង ការតម្រង់ទិសខាងគោលនយោបាយ ដល់ស្ថាប័ននីតិប្រតិបត្តិ ពោលគឺ **រដ្ឋាភិបាល** នៃប្រទេសនីមួយៗ ដើម្បីជំរុញអនុវត្តកម្មវិធីនយោបាយអភិវឌ្ឍន៍ប្រទេស និង គោលនយោបាយការបរទេសរបស់ជាតិ ។ ម៉្យាងទៀត, យើងទាំងអស់គ្នាយល់ដឹងយ៉ាងច្បាស់ថា **សភា** មានតួនាទីជាស្ពានដ៏សំខាន់សម្រាប់តភ្ជាប់ស្ថាប័ននីតិប្រតិបត្តិទៅនឹងប្រជាជន ។ ដូច្នេះ ទំនាក់ទំនងជិតស្និទ្ធរវាងរដ្ឋាភិបាលជាមួយនឹង **ស្ថាប័នសភា** នឹងផ្ដល់ឱកាសឱ្យស្ថាប័ននីតិប្រតិបត្តិ អាចស្វែងយល់បានយ៉ាងត្រឹមត្រូវអំពីបំណងប្រាថ្នា និង សេចក្ដីត្រូវការរបស់ប្រជាជន ហើយនឹងអាចចាត់វិធានការសមស្រប ដើម្បីបំពេញតាមបំណងប្រាថ្នា ព្រមទាំងឆ្លើយតបទៅនឹងសេចក្ដីត្រូវការទាំងអស់នោះ ។ ជាងនេះទៀត, ក្រៅពីការផ្ដល់នូវការគាំទ្រចាំបាច់ដល់កិច្ចការសំខាន់ៗរបស់រដ្ឋាភិបាល, ក្នុងនាមជាស្ថាប័ននីតិបញ្ញត្តិ, **សភា** ក៏មានតួនាទីក្នុងការពាំនាំយកទៅជម្រាបជូនដល់ប្រជាជនវិញ អំពីអ្វីដែលរដ្ឋាភិបាលបានធ្វើសម្រាប់ជាផលប្រយោជន៍ដល់ប្រជាជាតិរបស់យើងនីមួយៗ ដើម្បីបណ្ដុះ និង ពង្រឹងនូវ **«ស្មារតីនៃការចូលរួម»** ដែលមានសារៈសំខាន់ជាខ្លាំង សម្រាប់ការលើកកម្ពស់សាមគ្គីភាព, ឯកភាពជាតិ និង ភាព-សុខដុមរមនាក្នុងសង្គម ព្រមទាំងសម្រាប់ការពង្រឹង និង ពង្រីកកិច្ចសហប្រតិការជាអន្តរជាតិ ដែលទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាននៃការធានាសុខសន្តិភាព និង ការលើកស្ទួយការអភិវឌ្ឍ ។

ក្នុងន័យនេះ ការប្រារព្ធមហាសន្និបាតលើកទី ៨ នៃសភាតំបន់អាស៊ី ក្រោមប្រធានបទ **«ការជំរុញសន្តិភាព, ការផ្សះផ្សា និង ការសន្ទនា នៅតំបន់អាស៊ី»** នាពេលនេះ គឺជាឱកាសមួយដ៏សំខាន់សម្រាប់ក្រើនរំឭកអំពីភាពចាំបាច់ខ្វះពុំបាននៃការពង្រឹងសាមគ្គីភាព, ឯកភាពជាតិ និង កិច្ចសហការពួតដៃគ្នាជាធ្លុងមួយរវាងបណ្ដាប្រជាជាតិ ដើម្បីធានាថែរក្សាឱ្យបានគង់វង្សនូវសុខសន្តិភាព, ទាំងក្នុងកម្រិតជាតិ, កម្រិតតំបន់ និង កម្រិតពិភពលោក, តាមរយៈការលើកកម្ពស់វប្បធម៌អហឹង្សា និង វប្បធម៌សន្ទនា, ការអត់ធ្មត់ និង ការយោគយល់គ្នាជាភាតរៈ, ការនិយមកណ្ដាល និង ការ-ដោះស្រាយទំនាស់ និង បញ្ហាវិវាទផ្សេងៗ ដោយសន្តិវិធី និង ដោយឈរលើគោលការណ៍នៃច្បាប់ជាតិ និង អន្តរជាតិ, ទាំងនៅក្នុងសង្គមជាតិរបស់យើងនីមួយៗ, ទាំងរវាងប្រទេសជាតិយើងនីមួយៗ ។

ក្នុងស្មារតីនេះ ខ្ញុំសង្ឃឹមថា ឯកឧត្ដម លោកជំទាវ ជាប្រតិភូមកពីសភាតំបន់អាស៊ី នឹងចូលរួមពិភាក្សាយ៉ាងសកម្មលើប្រធានបទនៃអង្គមហាសន្និបាតលើកទី ៨ របស់យើងនាពេលនេះ ដោយធ្វើការចែករំលែកចំណេះដឹង, ព្រមទាំងបទពិសោធន៍ក្នុងការកសាងសន្តិភាព និង ការថែរក្សាសន្តិភាព ដើម្បីជាឧត្តមប្រយោជន៍ដល់ប្រជាជនយើងទាំងអស់គ្នា ។ លើសពីនេះ ខ្ញុំសូមលើកទឹកចិត្តដល់អង្គមហាសន្និបាត ឱ្យធ្វើការពិភាក្សាលើប្រធានបទនេះក្នុងន័យទូលាយ ដោយមិនត្រឹមតែផ្ដោតទៅលើការពង្រឹង និង ការថែរក្សាសន្តិភាពប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងខិតខំស្វែងយល់អំពីដំណើរការនៃការ-ដោះស្រាយជម្លោះ និង ការទប់ស្កាត់ជម្លោះក្នុងប្រទេសនានា នៅក្នុងតំបន់ថែមទៀតផង ។

ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និង ការវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ហើយសូមជូនពរឱ្យលោកអ្នកទាំងអស់គ្នាទទួលបាននូវការស្នាក់នៅប្រកបដោយសេចក្តីរីករាយ និង មានផាសុខភាព ។

**ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់ !**

Speech

By

Samdech Akka Moha Sena Padei Techo HUN SEN

Prime Minister of the Kingdom of Cambodia

At the

Opening of 8th Plenary Session of the Asian Parliamentary Assembly

Under the theme of "Promoting Peace, Reconciliation and Dialogue in Asia"

Phnom Penh, December 9, 2015

- *Excellency **MIAN Raza Rabbani,** Chairperson of the Asia Parliamentary Assembly,*
- *Samdech Vibol Sena Pheakdei **SAY Chhum,** President of the Senate of the Kingdom of Cambodia*
- *Samdech Akka Moha Ponhea Chakrei **HENG Samrin,** President of the National Assembly of the Kingdom of Cambodia*
- *Excellency **NEJAD Hosseinian,** Secretary General of the Asia Parliamentary Assembly*
- *Excellencies, Members of delegations from Asia Parliamentary Assembly, non-member observer states and observer non-governmental organizations*
- *Excellencies, Ladies and Gentlemen and Distinguished local and International Guests!*

Today, I am very pleased and honored to attend the opening ceremony of the 8th Plenary Session of the Asian Parliamentary Assembly (APA) to be hosted by the Kingdom of Cambodia. On behalf of the Royal government and people of Cambodia, I would like to extend my warmest welcome to APA member parliaments of the delegates from Asia region, delegations from APA observer parliaments and other APA observer non-governmental organizations who have gathered for this historical event. Indeed, the Kingdom of Cambodia is proud to host this plenary session of the Asia Parliamentary Assembly.

The 8th Plenary Session of the Asian Parliamentary Assembly under the theme of **"Promoting peace, reconciliation and dialogue in ASIA"** is indispensable as it does not only inspire us to be aware and collectively response to the current evolving situation in the region and the globe where civil war has been broken out in some area and terrorism network has been spread that is extremely dangerous for the nations as a whole, but it also contributes to the comprehensive understanding of the meaning and the value

of peace and the necessity of everyone's cooperation internationally in preventing, reducing, and put an end in armed conflicts and wars everywhere around the world.

Based on this theme, may I share realistic experience that Cambodia has faced in undergoing wars that has caused indescribable suffer to all Cambodian citizens, which left scars that are not completely healed until now. As you all may already recognize that, at the beginning of this past millennium, Cambodia had reached the highest level of noticeable success. We used to consume modern technology in that era in several fields such as architecture, agriculture, urban planning, construction and other renovations. Nevertheless, civil and world wars, that caused by the internal fragmentation since the 14th century and came with the ideology conflict with the external powers in this last decades of the 20th century, have drawn Cambodia into the pit of darkness. In the early 1970s, Cambodia had suffered a severe fragmentation via coup on the 18th March, 1970 that led by marshal **Lon Nol** to overthrow **King Norodom Sihanouk**'s regime. This had drawn Cambodia into severe war during the time. Tons of bombs had been dropped within the land of Cambodia, millions of people had lost their lives, become disables, perished from families and lost all wealth. Reaching the mid-1970s, Cambodia had suffered further destructions under the Killing Fields regime of Khmer Rouge. This regime had taken the freedom of the citizens and had killed around three million lives of the innocents.

On the 7th January 1979, the whole nation and Cambodian citizen had been rescued from the genocidal regime of **Pol Pot** by the armed forces of the Khmer United Front for National Salvation. Since then, Cambodia has made great efforts to build and develop its economy and society under the circumstance of **"war's existence and peace's existence".** Having realized the demand and wishes of the people for peace, we started the negotiation to seek political solution until we achieved "**Paris Agreement**" in 1992. According to this agreement, international community had prepared for the universal election for Cambodia in 1993.This election had created coalition which left with one partner staying outside of the society and continued the war against the government. Until 1998, through the implementation of the national "**win-win"** policy, Cambodia had achieved physical and political unification and reconciliation of the nation by itself without external injunctive or persuasive. Based on this principle, Cambodia put an end of the decade of chronic war and then brought full peace, independent, and territorial integrity, with the effort of unification and reconciliation of the nations via **mutual compromise and concession.**

This is the historic truth of the development process that Cambodia has made, so that we clearly understand the value of peace that we never wish to lose again. The fruit of peace has also greatly contributed to strengthening democracy, respect for human rights and dignity. These experiences make Cambodian people to strongly commit to promote the principle of national reconciliation, protect peace, stability and social order, obedience to the constitution and rule of law in order to serve as a common benefit for the people, society and the whole country.

Obviously, the peaceful way to completely put an end of the civil war can be achieved with tremendously great effort. But, maintaining full peace and strengthening the culture of dialogue are even more difficult task. In this spirit, we have to work smart and make double efforts to take full care of key factors that are requisite foundation for peace, including enhancing the culture of non-violence, respect for rights and integrity of human being, promoting democracy and good governance and strictly adhering to the principle of "**Rule of law**", particularly eradicating poverty in the country and improving the standards of living. It is true that if there was no great effort and no realistic result in the implementation of such tasks, we cannot maintain full peace as we have been so far enjoyed it.

- *Excellencies, Ladies and Gentlemen and all participants*

Currently, peaceful situation in the number of regions in the world has been threatened by domestic conflict, war and terrorism that cause the great loss of human lives and wealth. Recent incident occurring in the central Paris of France, Russian plane crash in Egypt caused by bomb planted by terrorist and California shooting in the United State reassure that terrorist and extremist movement remain serious threat to security and stability in the world. In addition, we have noticed clearly that extremist movement and extremism have spread from one region to another region, including Asia.

Therefore, the world has now faced many great challenges such as uncertainty of economic recovery of the developed countries, prolonged debt crisis in Europe and slower economic growth of the emerging counties such as China, political deadlock and social issue that are occurring in middle east and north Africa, food security and energy issue, climate change, national disaster, cross-border crime have inflicted instability and security of all nations in both regional and global level.

In this regard, the deepening of international cooperation and partnership at all level is indispensable in tackling great challenges, aimed to ensure sustainable development, stability, security and peace as well as social harmonization. It is true that the concerted efforts that we have exerted are

unable to produce expected satisfactory result if there are no active participation and support from every level of our people, particularly youth and private sector. Therefore, our high priorities are given to promote participation of our people in all activities in longer term.

Within this, I am of the view that in the great efforts to strengthen international cooperation among the countries and people and promote the participation, legislative branch of respective country, in particular "**parliamentary institution**" indeed plays essential role in the process. As the legislative branch of respective country, Assembly plays important role in developing regulatory framework and rectifying regulations that help support and shape policy direction for executive branch, "government" of respective country to promote the implementation of national development policy program and its foreign policy. In addition, we have to understand that parliament plays the important role as a bridge to connect legislative branch with people. Therefore, close cooperation between government and legislative branch provide auspicious opportunity for executive branch to understand clearly about the wish and the need of our people and then take rational action to fulfil their wish in order to respond to their need. Moreover, in addition to providing necessary supports to key tasks of the government, Parliament also has to pay role in conveying all achievement made by government to their people with an objective to germinate and strengthen the "**participation spirit**" which is very important tool for enhancing solidary, territorial integrity and social harmonization as well as for strengthening and expanding international cooperation that are prerequisite for ensuring full peace and sustaining development.

In this spirit, the organization of the 8th Plenary Session of Asia Parliamentary Assembly under the theme of "**Promoting peace, reconciliation, dialogue in Asia**" has provided auspicious opportunity to remind necessity for strengthening solidary, territorial integrity and close cooperation among the member countries to ensure full peace at national, regional and global level through promoting culture of non-violence and dialogue, strong patient and mutual respect, balancing and peaceful dispute settlement based on the principle of respective country's rule of law and international law.

In this regard, we should announce commitment of all respectable international documents includes United Nations' Charter, United Nations' Pacts, other conventions that go against the wars and promote peace, and all conflict resolution is resolved with peace and stood by the essential international laws framework. Moreover, we all should promote relationship, friendship, and cooperation among nations in all fields. Within this, we should extensively

advertise on the understanding of foundation that supports peace such as promoting non-violence culture and culture of dialogue, tolerant with and forgiving each other in our societies.

In this spirit, I believe that APA member parliaments of the delegates from Asia region will actively participate in discussion about the topic of this $8^{th}$ plenary session by sharing knowledge and experience in making peace and security to serve as a benefit for the people living in Asia and in the world. In addition, I would like to encourage participants to discuss this topic in broader context by not only center on strengthening peace and security, but also learn the process of dispute settlement and prevention of dispute from happening in countries and in the region.

Once again, I would like to express my warmest welcome and highly appreciate the presence of Your Excellencies, Ladies and Gentlemen, and may I wish you all a pleasant and memorable stay in Cambodia.

***Thank you!***